# បាលីវេរកឋិនទាន

ឥមំ   ភន្តេ   កឋិនចីវរំ   សានិសង្សំ   សង្ឃស្ស   ទេម ។  (៣ចប់ឬ៣ដង)

សាធុ នោ ភន្តេ សង្ឃោ ឥមំ កឋិនចីវរំ សានិសង្សំ បដិគ្គណ្ហតុ កឋិនំ អត្ថរិតុំ

មាតាបិតុអាទិនញ្ច គុណវន្តានំ អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

*បពិត្រ ព្រះគម្ដែងសង្ឃដ៏ចំរើនឡើយ យើងខ្ញុំទាំងឡាយ សូមវេរប្រគេននូវកឋិនចីវរនេះ ព្រមទាំងអានិសង្សលាភចំពោះព្រះសង្ឃ ។ បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើន សូមព្រះសង្ឃមេត្តាទទួលយកនូវកឋិនចីវររបស់យើងខ្ញុំទាំងឡាយនេះ ព្រមទាំងអានិសង្សលាភ ដើម្បីក្រាលកឋិន, ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ, ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង, ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាយូរអង្វែងទៅហោង ។*

វេរគ្រឿងបរិក្ខារជាបរិវារកឋិនថាដូច្នេះ

យេនម្ហាកំ   កឋិនំ   កឋិនានិ   សំសានិ   តស្សេវ   ទេម ។

ទុតិយម្បិ   យេនម្ហាកំ   កឋិនំ   កឋិនានិ   សំសានិ   តស្សេវ   ទេម ។

តតិយម្បិ   យេនម្ហាកំ   កឋិនំ   កឋិនានិ   សំសានិ   តស្សេវ   ទេម ។

*បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើនឡើយ រីកឋិនទាននៃយើងខ្ញុំទាំងឡាយ គឺព្រះសង្ឃអង្គណាបានទទួលកាន់យកហើយ យើងខ្ញុំទាំងឡាយសូមវេរនូវគ្រឿងបរិក្ខារជាបរិវារនៃកឋិនទាំងឡាយ ប្រគេនចំពោះ-ព្រះសង្ឃអង្គនោះ ។   អស់វារៈពីរដងផង ។   អស់វារៈបីដងផង ។*

របៀបវេរនេះ យើងខ្ញុំដកស្រង់ចេញពីសៀវភៅប្រស្នាគិហិប្រតិបត្តិពិស្ដាររបស់លោកបណ្ឌិត **ឈឹម   ទូច**

ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ម៉ាន់   អ៊ុន**   អាចារ្យទី១សម្រាប់វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣

វាយចម្លងដាក់គេហទំព័រវត្ត ដោយខ្ញុំព្រះករុណាខ្ញុំបាទ **អ៊ុន   លី**  ថ្ងៃទី៩  ខែឧសភា  ឆ្នាំ២០១២